Developed by the
Minnesota Department of Health,
Tuberculosis Prevention and Control Program
August 2002 phone: (612) 676-5414

This is one in a series of four patient education pamphlets that addresses TB to be used in various clinical situations.

# ជំងឺ
# របេង

**Tuberculosis Disease, Cambodian**

រោគរបេង(TB) គឺជាជំងឺធ្ងន់ណាស់ដែលបានកើតឡើងដោយមេរោគដែលអាចបង្កើនច្រើនឡើងនៅក្នុងខ្លួននិងធ្វើឱ្យខូចជាលិកា។ ភាគច្រើន វាតែងតែបណ្ដាលឱ្យខូចសួត ប៉ុន្តែវាអាចប៉ះពាល់សឹងគ្រប់កន្លែងទាំងអស់ក្នុងខ្លួន។ រោគរបេងឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតតាមខ្យល់អាកាស។

រោគរបេងនេះកើតឡើងដោយមេរោគដែលអាចបង្កើនច្រើនឡើងក្នុងខ្លួន

## អាការរោគនៃជំងឺរបេង

បើអ្នកមានជំងឺរបេងនៅក្នុងសួតរបស់អ្នក អ្នកប្រហែលៈ

- ក្អកជាច្រើន
- ក្អកចេញកំហាក
- ក្អកចេញឈាម
- មានឈឺដើមទ្រូងនៅពេលអ្នកក្អក

ទោះបីជាអ្នកមានរោគរបេងនៅក្នុងសួត ឬកន្លែងណាផ្សេងក្នុងខ្លួនអ្នក អ្នកប្រហែលជាៈ

- ចុះទម្ងន់ ស្គម
- មានរោគគ្រុនក្តៅ
- បែកញើសច្រើននៅពេលយប់
- ឈឺត្រង់កន្លែងនៃជម្ងឺនោះ

## ធ្វើតេស្តពិនិត្យថាតើអ្នកមានជំងឺរបេងឬទេ

តេស្តជាច្រើនដែលអាចត្រូវការធ្វើសំរាប់ពិនិត្យថាតើអ្នកមានជំងឺរបេងឬទេ។

ការធ្វើតេស្តសើស្បែកហៅថាម៉ែនធូ គឺជាមធ្យោបាយតែមួយគត់សំរាប់ប្រាប់ថា បើអ្នកបានដកដង្ហើមចូលដោយមេរោគរបេង។ តេស្តនេះជាធម្មតា គេធ្វើនៅលើដៃ។ កូនម្ជុលតូចមួយសំរាប់ប្រើចាក់បញ្ចូលទឹកថ្នាំ(ហៅថាទូប៊ែគ្គុលីន)នៅក្រោមស្បែក។ កន្ទួលតូចឬពណ៌ក្រហមមួយអាចកើតឡើងនៅលើស្បែក។ អ្នកត្រូវការទៅជួបពេទ្យនៅមន្ទីរព្យាបាលអ្នកក្នុងរយៈ២ទៅ៣ថ្ងៃក្រោយពេលធ្វើតេស្តនេះ ដើម្បីពិនិត្យលទ្ធផល។ ទោះបីជាអ្នកបានចាក់ថ្នាំBCG(Bacille Calmette-Guerin) ការពារកាលពីមុនក៏ដោយ អ្នកនៅតែអាចធ្វើតេស្តសើស្បែកម៉ែនធូបានដែរ។ ថ្នាំBCG មិនមែនការពារអ្នកពីរោគរបេងជានិច្ចបានឡើយ ហើយថ្នាំBCG ក៏មិនមានប្រតិកម្មអ្វីចំពោះការធ្វើតេស្តម៉ែនធូនៅលើស្បែកដែរ។

ការថតអិចរេលើដើមទ្រូង ត្រូវបានប្រើសំរាប់មើលថាតើមេរោគបានធ្វើឱ្យខូចដល់សួតអ្នកឬទេ។

អ្នកប្រហែលជាត្រូវគេសុំឱ្យក្អកចេញកំហាក ដែលគេនឹងយកទៅធ្វើតេស្តនៅមន្ទីរពិសោធន៍ សំរាប់ពិនិត្យមើលថាតើមានមេរោគរបេងនៅក្នុងសួតអ្នកឬទេ។

## ការពារការចម្លងរោគរបេងទៅអ្នកដទៃ

បើអ្នកមានជំងឺរបេងនៅក្នុងសួតអ្នក អ្នកអាចចម្លងមេរោគរបេងទៅអ្នកដទៃ។ មេរោគរបេងអាចរាយសាយទៅក្នុងខ្យល់ នៅពេលណាអ្នកក្អក ស្រែក ឬកណ្តាស់។

សូមគ្របមាត់ដោយប្រើកន្សែងឬក្រដាសជូតមាត់ជានិច្ច នៅពេលអ្នកក្អក! មនុស្សនៅជិតអ្នកអាចដកដង្ហើមដោយមេរោគរបេងចូលក្នុងសួតរបស់គេ។ នេះហៅថាការចម្លងរោគរបេង។ មនុស្សទាំងនេះគួរតែធ្វើតេស្តពិនិត្យ ថាតើគេមានការចម្លងមេរោគរបេងឬទេ និងគេត្រូវការថ្នាំសំរាប់ការពារកុំឱ្យឈឺដោយសារជំងឺរបេងនៅពេលក្រោយមក។

មេរោគរបេងមិនឆ្លងតាមម្ហូប ចានឆ្នាំង ក្រណាត់កំរាល ឬរបស់ផ្សេងៗទៀតទេ។

បើអ្នកមានជំងឺរបេងនៅកន្លែងផ្សេងៗក្នុងខ្លួនរបស់អ្នក (កន្លែងផ្សេងៗពីសួតរបស់អ្នក) អ្នកប្រហែលជាមិនចម្លងមេរោគរបេងទៅអ្នកដទៃឡើយ។

ជាការសំខាន់ណាស់
ក្នុងការបន្ត
ប្រើថ្នាំរបស់អ្នក



ក្រោយពីពេលដែលអ្នកបានប្រើថ្នាំអស់រយៈពេល២ឬ៣អាទិត្យមក ហើយអ្នកមានអារម្មណ៍ថា បានស្រួលគ្រាន់បើ អ្នកមិនអាចចម្លងមេរោគរបេងទៀតឡើយ។ អ្នកអាចត្រឡប់ទៅធ្វើការ និងធ្វើអ្វីផ្សេងៗទៀតបាន។ វាជាការចាំបាច់ណាស់ ក្នុងការបន្តការលេបថ្នាំដែលបានចេញឱ្យប្រើ សំរាប់សម្លាប់មេរោគរបេងនៅក្នុងខ្លួនរបស់អ្នក។